មជ្ឈមណ្ឌលឯកសារកម្ពុជា

TKI0768

# សម្ភាសន៍ជាមួយឈ្មោះ កម ញៀម ភេទប្រុស អាយុ៧០ឆ្នាំ
# មុខងារនៅសម័យខ្មែរក្រហមៈ អតីតអ្នកទោសនៅគុកក្រាំងស្វាយ
# សព្វថ្ងៃរស់នៅភូមិគោកព្រេច ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ
# ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០
# សម្ភាសន៍ដោយៈ គ្រី ស៊ុយហៀង និង ម៉ែន ពិចិត្រ
# ០១:០២:៥៥
# ២៧ទំព័រ

ហៀង ៖ ពូនៅក្រាំងស្វាយៗនៅណាវិញ?

ញៀម ៖ ក្រាំងស្វាយនៅភូមិក្រោម ។

ពិចិត្រ ៖ នៅភូមិអីអ៊ំ?

ញៀម ៖ នៅភូមិគោកព្រេច ។

ពិចិត្រ ៖ ឃុំអីគេ?

ញៀម ៖ គោកព្រេច ។

ពិចិត្រ ៖ ស្រុកគិរីវង់?

ញៀម ៖ គិរីវង់ ។

ហៀង៖ អ៊ំជាប់ហ្នឹងគេចាប់យកដាក់នៅហ្នឹងភ្លាម?

ញៀម ៖ គេចាប់មុនដំបូងចង់នៅកន្លែងឃុំគេនោះក្រោម នៅនឹងបានម៉ាខែ ។

ពិចិត្រ ៖ អ្នកណាគេទៅចាប់អ៊ំនឹង?

ញៀម ៖ ពួកខាងឃុំគេ ខាងនេះគេហៅឃុំគេអីគេនឹងអ្នកស្រុកគេនឹងមកពី១០៥ សុទ្ធពីលើអីមក គ្មានអ្នកនៅទេ ។

ពិចិត្រ ៖ អ៊ំមានស្គាល់គេទេ?

ញៀម ៖ ស្គាល់ឈ្មោះកាលហ្នឹង ប៉ុន្តែឥលូវមិនដឹងគេទៅខាងណាបាត់អស់ហើយ ។

ពិចិត្រ ៖ ឈ្មោះអីគេដែរអ៊ំ?

ញៀម ៖ ឈ្មោះ ណៃ អានឹងប្រធានឃុំគេ ។

ពិចិត្រ ៖ ប្រធានឃុំៗអីគេដែរ?

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ញ៉ោម : ប្រធានឃុំគេមកនៅកាន់ឃុំហ្នឹង ប៉ុនមិនដឹងគេនៅណាដែរ ។ គេមកពីលើគេហៅ១០៥ៗ គេមក គេមកនៅនឹង ។ ទាល់តែយកពីឆ្ងាយមកនៅ យើងអត់ស្គាល់កន្លែងមូលដ្ឋានគេនៅណាឯណាអត់ដឹង ។

ហៀង : អ៊ំជាប់គុក គេឲ្យអ៊ំធ្វើអីដែរ មានដាក់ច្រវ៉ាក់ទេ?

ញ៉ោម : អួយ! ជាប់មុនដំបូងពិបាកមាំណាស់នៅនោះ១ខែ៤ថ្ងៃនឹង ត្រូវគេបំបិទនៅលើផ្ទះហ្នឹង វ៉ារត់រួចណា ។ រត់រួចថ្ងៃហ្នឹងពីល្ងាចចឹង ថ្ងៃហ្នឹងត្រូវគេចាប់ខ្ញុំទៅ សុទ្ធតែពិការចំណង នេះដើងទៀត ។

ហៀង : គ្រាន់តែចង?

ញ៉ោម : ចង ហើយចង ។

ហៀង : គេមានដាក់ច្រវ៉ាក់ ដាក់គុកទេ?

ញ៉ោម : ហើយចងចឹងហើយ ពេលថ្ងៃគេដាក់នៅខ្សែ ប៉ុននៅចងជាប់សសរនេះ ម្នាក់មួយៗគ្រប់ជ្រុងសសរលើផ្ទះចឹង ។ ហើយគេដេកពីក្រោម ហើយយើងលាន់ខ្សែក្រៀក ប៉ុនរនាបឫស្សី មិនមែនរនាបយើង បែបនេះដេកបុកខ្នងញល់ៗតែលាន់ខ្សែបន្តិចមិនបានផង ។ ហើយមិនបាន១៨ខែហ្នឹងហើយ តាំង១ខែ៤ថ្ងៃនៅនេះគិតទៅវ៉ា១៧ខែ ។

ពិចិត្រ : ហើយអ៊ំនៅគុក១៧ខែហ្នឹង គុកឈ្មោះអីដែរ មិញភ្លេចបាត់ហើយអ៊ំ?

ញ៉ោម : ក្រាំងស្វាយ ។

ពិចិត្រ : នៅភូមិរ?

ញ៉ោម : ភូមិគោកព្រេច ។

ពិចិត្រ : ឃុំគោកព្រេចដែរ?

ញ៉ោម : ឃុំគោកព្រេច ។

ពិចិត្រ : ហើយពីណាគេជាប្រធានគុកអី ពូមានស្គាល់?

ញ៉ោម : ប្រធានគុកហ្នឹង ហ៊ីប៉ិព្រីងអីហ្នឹង ឈឹមអីនឹង សុទ្ធតែងាប់អស់ហើយ គ្រាន់តែស្គាល់ឈ្មោះ ប៉ុនស្រុកគេមិនដឹងនៅណា ។

ពិចិត្រ : ហើយចុះអ៊ំនៅក្នុងគុកហ្នឹង សភាពម៉េចទៅ អ៊ំអាចនៅចាំដែរទេ?

ញ៉ោម : ជីហ្នឹងចាំៗទាំងអស់ប្រវត្តិនឹងអត់ភ្លេចទេ ។

ពិចិត្រ : អ៊ំអាចរៀបរាប់បានទេ?

ញ៉ោម : អីនឹងបានរៀបរាប់ ។ នៅក្នុងហ្នឹងមុនដំបូងខ្ញុំទាំងអស់មាន៧នាក់ចូលក្នុងហ្នឹង ។ ៧នាក់នឹង

គុកហ្នឹងគេធ្វើហើយថ្មីចេស ។ ចូលទៅដល់នៅចឹងទៅ គេឲ្យបាយគេបបរមួយចានៗ ប៉ុន គ្រាប់បាយប្រហែលជា២ស្លាបព្រាយ៉ាងច្រើន ។

ពិចិត្រ : ម៉េចទៀតអ៊ំ?

ញ៉ោម : គេឲ្យស៊ីបាយទទេរពេលៗចឹងទៅ ប៉ុន្តែបាយវាខ្សោះៗចឹងទៅ ។

ពិចិត្រ : ហើយ៧នាក់ហ្នឹងអ៊ំមាននៅចាំឈ្មោះ ៧នាក់ដែលជាប់ជាមួយអ៊ំ?

ញ៉ោម : ជាប់នឹងថឺមិនចាំ ។

ពិចិត្រ : ឈ្មោះអីខ្លះ?

ញ៉ោម : ប៉ុនស្លាប់អស់ហើយក្មួយ ឥឡូវមាននៅសល់ បើមានកុងឃីមនេះស្លាប់ហើយ, យុនស្លាប់ ហើយ, បុស៊ុនស្លាប់ហើយ តានេះនឹងសុទ្ធតែស្លាប់នៅនឹង ។ អ្នកហ្នឹងនៅជាប់បានយូរៗ ដល់៧៥មក អានឹងគេត្រូវសើររើអាពួកគេហៅថា១៧នោះ ចូលហើយ ។ ម៉ាថ្ងៃមាន ២០-៣០ យកចេញក៏២០-៣០ចឹង ។ យកចេញៗទៅគេថាយកទៅរៀននៅលើ យក ទៅមិនដឹងទៅរៀននៅឯណា ។

ពិចិត្រ : ហើយអ្នកទាំង៧អ្នកហ្នឹង អ៊ំមានដឹងថាហេតុអីបានជាគេយកមកដាក់គុកនៅនឹង?

ញ៉ោម : ៧ហ្នឹងសុទ្ធតែមូលហេតុមានដូចគ្នា អ្នកអារឿងជាមួយខ្ញុំ មានបងថ្លៃខ្ញុំមួយ តាកេងហ្នឹង ២ ហ្នឹងសុទ្ធតែស្លាប់អស់ហើយ តាកេងហ្នឹងគេយកនៅកន្លែងហ្នឹង គេសួរថាអង្គការគេ ហ្នឹង គេជួយដោះស្រាយបានឲ្យតែឆ្លើយត្រង់ជាមួយគេ ។ ដល់ឆ្លើយត្រង់ជាមួយគេ តាហ្នឹងប្អូនគាត់ៗរត់ចុះស្រុកយួនដែរ ។ ដល់ចឹងគាត់ប្រាប់ត្រង់ថា ប្អូនគេសួរថាចុះរឿងស្អី បានមកជាប់ហ្នឹង ថា“ប្អូនរត់ចុះស្រុកយួន” ។ ដល់ចុះប្អូននឹងរត់ចុះស្រុកយួនចឹង គេ ថាប្អូនហ្នឹងមកនៅភ្នំដូចយើងនេះ សួរថាគេចោទថាមានឲ្យអង្ករឲ្យមាន់អីហ្នឹង មានឲ្យមែន ទេ? គាត់ឆ្លើយត្រង់ គាត់ប្រាប់ត្រង់ ចុះពុកគេថាឲ្យតែប្រាប់គេត្រង់គេឲ្យរួចនោះ គាត់ថាបានឲ្យមែន បានឲ្យអង្ករបានឲ្យមាន់ ប្រាប់គេត្រង់ឆ្លើយចឹងទៅ ។ ដល់ចឹងប្រហែល ជាម៉ោង៤ថ្ងៃរសៀល ចឹងតានេះត្រូវរួច ចឹងមុននឹងរួចគេសុំចងការពារអាយុជីវិត ក្រែង យើងភ័យពេករត់អីទៅគេបាញ់ស្លាប់ ទៅរៀន៧ថ្ងៃត្រូវតាឯងទៅជួបជុំគ្រួសារវិញហើយ ចឹងក៏ចាប់យកគាត់ទៅ យកទៅគេធ្វើទំបន់នៅណាទេ ពោធិវ៉ាទៅជួយធ្វើបង្គីរមួយ អាទិត្យសិន ចាំគេឲ្យរួចទៅផ្ទះទៅជួបជុំគ្រួសារ ។ ដល់ចឹងយកបាត់ចេញបាត់ទៅ ហើយ ខ្ញុំនៅជាប់ហ្នឹង ។ ដល់គេសួរខ្ញុំម្ដងវិញទៀត គេសួរចុះពូនេះត្រូវយ៉ាងម៉េចដែរ? ខ្ញុំថាដូចប្អូនទៅស្រុកយួនដែរ ។ ហើយចោទថាយកឲ្យអង្ករ ឲ្យមាន់ចឹងដែរ ។ ប៉ុនខ្ញុំអត់បាន

ឲ្យទេ ខ្ញុំអត់ដឹងផង មិនដឹងគេមកអីផង ។ ខ្ញុំអត់បានឲ្យ ហើយខ្ញុំមែន ខ្ញុំឆ្លើយតាមត្រង់ មិនបានដឹងមិនបានឲ្យអីអត់បាន មិនដឹងវាមកផង ឆ្លើយតាមចឹងទៅ ។ ដល់ចឹងទៅរួចខ្ញុំទម្រាំរួចហ្នឹងមើលគិតទៅ គិតទៅ១៨ខែវា ៣ឆ្នាំណា ចុង៧៣ដើម៧៦បានរួច គិតជាខែ ១៨ខែ ប៉ុនជាប់កន្លែងនោះតែ១ខែ៨ថ្ងៃទេ ។

ពិចិត្រ : ចឹងអ្នកសួរអុំហ្នឹងឈ្មោះអ៊ីដែរ អុំមានស្គាល់ឈ្មោះដែរទេ?

ញ៉ោម : អ្នកសួរហ្នឹងប៉ុព្រឹងអីហ្នឹង គេធ្វើបាបរប៉ាត់រប៉ាយអស់ហើយ កាល៧៩អីហ្នឹងមកពួកខាងនេះ ពួកគេថាព្រួតគ្នាវ៉ៃអីងាប់បាត់ណារប៉ាត់រប៉ាយ ប៉ុមួយរត់ទៅណាគេវ៉ៃនៅកំពែងនោះវ៉ៃទៅណាវាលរេញ ឈិននឹង អានឹងទៅបាត់ងាប់ណា ។ នៅមិនបានទេ កាលចុះមក៧៩ អ្នកធ្វើចឹង ៗ នៅមិនបានទេ មកប្រជាជនវ៉ៃខ្ទេចខ្ទីអស់ ។

ពិចិត្រ : ចុះប្អូនអុំដែលរត់ទៅស្រុកយួនហ្នឹង ឈ្មោះអីដែរ?

ញ៉ោម : ឈ្មោះ ណន ។

ពិចិត្រ : ត្រូវជាអ៊ី ប្អូនបង្កើត ហើយប្អូនថ្លៃ?

ញ៉ោម : ប្អូនថៃ្ល ដល់ឆ្នាំ៧៥វាឡើងទៅចឹងចូលមកភ្នំពេញ ដល់៧៥វាចុះមកពីភ្នំពេញមក គ្រាន់តែដល់ផ្ទះ គេឃាត់ សុំគេស៊ីបាយសិន គេមិនព្រមទេ គេយកទៅភ្លាមមួយរំពេច ។

ពិចិត្រ : ក្រោយមកគេចាប់គាត់វិញ បាន?

ញ៉ោម : ចាប់បាន ។ ដល់ពេលបែក៧៥វានៅភ្នំពេញគេចុះមក ។

ពិចិត្រ : ហើយគេចាប់គាត់យកទៅណាដែរ អុំមានដឹង?

ញ៉ោម : យកទៅ ៗ ជួបគ្នាយកទៅបញ្ចូលគុកនឹងដដែល ខ្ញុំភ័យបុកពោះ ថាអត់ដឹងចម្លើយវាម៉េចវានឹកឃើញថា បែបងាប់ដែរហើយមិននៅ ។ វាឆ្លើយម៉េចអីម៉េចទេ ទៅវាអត់អីដែរខ្ញុំ ទៅជាបានរួចទៅវិញ ។

ពិចិត្រ : ចុះអុំនៅក្នុងគុកហ្នឹង?

ញ៉ោម : រួចម៉ាគុកនឹង គិតទៅគ្នាមនុស្សរាប់ម៉ឺននាក់ គេថាម៉ាស្រុក១០៩ហ្នឹង រាប់ម៉ឺននាក់ រស់ចេញតែ១៦នាក់ទេ ។

ហៀង : ក្នុងគុកហ្នឹងអុំ! តើជាប់ប៉ុន្មាននាក់ដែរ?

ញ៉ោម : គុកហ្នឹងចូលនឹងរាប់ម៉ឺននាក់ ប៉ុនតែមែននៅរស់ទេ ចូលថ្ងៃហ្នឹង២០-៣០ ចេញក៏២០-៣០ដែរ គេយកចេញ គេថាបញ្ជូនទៅលើទៀត មិនដឹងគេយកទៅណា ។ គេយកទៅហ្នឹងវាយកទៅកាលឆ្នាំ៧០ប៉ុន្មានទេ អាបេវ៉ៃហ្នឹង ៧៣ហ្នឹងប្រជាជនយើងដឹកត្រង់សេ គ្រប់

វាលស្រែអីហ្នឹង ដឹកសុទ្ធតែធ្វើរូងនៅ យាយពីគ្មានទេញាត់ពេញៗទាំងអស់ ទុកពួនកប៉ាល់ហោះ ។

អ្នកចូលរួមៈ ហើយលើនេះ ចុះមកគេមិនយកពួកអាធ្វើប៉ុលពតមកកាយ យកមកកាយ ។

ជាតិ : កាយយកឆ្អឹងចេញ?

អ្នកជិតខាង : បាទ! ហើយឥលូវគោស៊ីអស់ហើយ ។

ញ៉ោម : ច្រើនណាស់ពេញៗរណ្ដៅ ហើយប្រជាជនក្នុងមួយភូមិហ្នឹងទៅធ្វើរុននៅវាលស្រែ កាលអាបេវ៉ែនោះ ។ ញាត់ពេញៗ អាខ្លះណាមិននេះផង អាខ្លះយកតែព្រៃនៅឯងដល់ចុះប្រជាជនមានគេមានហ៊ានឲ្យដើរទៅណា អត់មានដើរទៅណាទេ មានតែពួកគេទេដើរយកទៅវ៉ៃចោលនៅឯរាប់ឯង ទាំងខ្សែៗនោះ ។

ពិចិត្រ : បាទ! ចង់ត្រលប់សួរមកពីគុកវិញ គុកហ្នឹងមានទំហំប៉ុនណាដែរ អ៊ំអាចដឹងដែរទេ?

ញ៉ោម : គុកហ្នឹងវាធំប្រហែលជា៦-៧ម៉ែត្រ បណ្ដោយប្រហែលជា៧-៨ម៉ែត្រនោះ ប៉ុនជញ្ជាំងក្ដារ គេវ៉ៃក្ដារ ។ ហើយគេធ្វើពុះពាក់កណ្ដាលចេះ .ម្ខាងដេកលើក្ដារ ម្ខាងដេកលើដីគេធ្វើឈើចឹង គេវាលៗយប់ឡើង គេឲ្យដាក់ជើង គេដាក់ថ្នងជើង គេសកជើងចូល ក្នុងហ្នឹងទាំងអស់ ហើយគេវ៉ៃឈ្នាតគេនៅក្រៅនោះ ។ ដល់ខ្ញុំរួចចេញមក គុកហ្នឹងគេសើរើទៅនៅខាងវត្តព្រះធាតុ ប៉ុនឃុំគោកព្រេចដដែលហ្នឹង ។

ហៀង : អូហ៍! ចឹងគេរើពីគុកហ្នឹងទៅដាក់នៅគុកព្រះធាតុវិញ ?

ញ៉ោម : ដល់នេះវាចង់ពុកផុយ ។

ហៀង : ចឹងមានន័យថាគុកនេះគេរើពីនេះទៅ លោកតា?

ញ៉ោម : រើពីនេះទៅ ។

ហៀង : ចឹងមានន័យថារើពីគុកហ្នឹងទៅយកទៅដាក់គុកព្រះធាតុ ម៉េចអ៊ំដឹង?

ញ៉ោម : ខ្ញុំរួចហើយកាល ហើយកាលចេញពីនេះទៅខ្ញុំរួចនៅនេះ ។

ហៀង : ម៉េចបានជាអ៊ំដឹងថាអាហ្នឹងគេរើយកទៅដាក់នៅគុកព្រះធាតុវិញ?

ញ៉ោម : ថីមិនដឹង ចុះបើយើងនៅក្នុងភូមិហ្នឹង ព្រះធាតុក៏នៅក្នុងឃុំគោកព្រេចដែរ ប៉ុន្តែចុងឃុំខាងកើត ។

ហៀង : ចុះអ៊ំនៅក្នុងគុកដែលអ៊ំជាប់ហ្នឹងអ៊ំមានឃើញដូចថាគេសួរចម្លើយ គេសួរយ៉ាងម៉េច ដែរឬគេមានកត់ត្រា មានអីដែរអត?

ញ៉ោម : គេសួរហ្នងហើយ!

ហៀង ៖ គេសួរមួយថ្ងៃប៉ុន្មានដង?

ញ៉ោម ៖ សួរក្នុងមួយខែហ្នឹងដូន២-៣ដង ដូចតែពីខាងភ្នាក់ងារគេនៅក្នុងស្រុក មុនដំបូងគេចាប់ទៅខាងឃុំគេសួរ ដល់នេះស្រុកគេ ដល់នេះដឹងស្អីគេខ្លះទេ មកសួរសួរនេះសួរ ។

ហៀង ៖ គេមានវ៉ៃទេអ៊ំ ពេលសួរហ្នឹង?

ញ៉ោម ៖ ខ្ញុំក្រៅពីហ្នឹងគេវ៉ៃ ប៉ុន្តែខ្ញុំដូចជាអត់មានគេវ៉ៃ ។

ហៀង ៖ តែអ្នកផ្សេងវ៉ៃដែរ?

ញ៉ោម ៖ អូហ៍! វ៉ៃណាស់ ខ្ញុំបើគេវ៉ៃងាប់បាត់ហើយមនុស្សឈឺសព្វជម្ងឺផង!

ហៀង ៖ បាយទឹកអីម៉េចដែរអ៊ំ?

ញ៉ោម ៖ បាយទឹកហ្នឹងគេហូបសោះតាខាន បបរមួយចានតែប៉ុណ្ណឹង កាកបាយ២,៣ស្លាបព្រាហ្នឹងមានតែទឹកហ្នឹង ។

ហៀង ៖ មួយថ្ងៃប៉ុន្មានដងអ៊ំ?

ញ៉ោម ៖ មួយថ្ងៃមានតែពេលព្រឹកហូប ថ្ងៃត្រង់ ដល់ហូបពេលល្ងាចហ្នឹងប្រហែលជាម៉ោង៤គេឲ្យហូប ។

ហៀង ៖ ចុះពេលដែលហូបហ្នឹងគេមានស្រាយចំណងឲ្យយើងទេអ៊ំ?

ញ៉ោម ៖ អាហ្នឹងដល់មកជាប់នេះគេដាក់តែជើងទេ ពេលថ្ងៃគេដោះ ប៉ុន្តែនៅតែក្នុងហ្នឹងដដែល ប៉ុនវបរលួសនៅព័ទ្ធជុំវិញ ពេលដែលហូបហ្នឹងគេឲ្យមានចុងភៅគេចូលទៅចែកនៅក្នុងហ្នឹង ។

ហៀង ៖ ចា៎! អូហ៍មានចុងភៅចូលយកទៅចែកក្នុងហ្នឹង?

ញ៉ោម ៖ ចែកនៅក្នុងគុក ។

ហៀង ៖ ចុះអ្នកយាមនៅក្នុងគុកហ្នឹងគេមានធ្វើអីខ្លះទេអ៊ំ?

ញ៉ោម ៖ អ្នកយាមសុទ្ធតែកាំភ្លើង ការពារនៅពេញហ្នឹង!

ហៀង ៖ម្នាក់កាន់កាំភ្លើងប៉ុន្មាន?

ញ៉ោម ៖ ម្នាក់១ដើមៗ កាំភ្លើងគេក្នុងហ្នឹង ដូចថារោងគុកចឹងទៅ កន្លែងផ្ទះគេការពារនៅពីមុខចឹងធ្វើរោងប៉ុនគេដេក ប៉ុន្តែគេត្រឹមត្រូវ ស្រួលបួលនៅការពារហ្នឹង

ហៀង៖ គុកហ្នឹងកាលឆ្នាំ៧៦ ដល់ពេលអ៊ំរៀបចេញមានប្រហែលជាប៉ុន្មាននាក់ទៀតនៅជាប់នៅហ្នឹង?

ញ៉ោម ៖ កាលខ្ញុំចេញហ្នឹង អរដល់ពេល៧៥ហ្នឹងជម្លៀសអ្នកមកពីភ្នំពេញហ្នឹង គេឲ្យចេញទៅក្រៅហើយ ។

ហៀង ៖ អូហ៍! គេឲ្យចេញទៅក្រៅហើយ!

ញ៉ោម ៖ បាទ! ដល់គេយកពួកថ្មីៗហ្នឹងមកដាក់ម្តង គេឲ្យចេញទៅក្រៅហ្នឹងគ្នាមាន១៦នាក់

ហៀង ៖ ចេញទៅក្រៅណាអ៊ី?

ញ៉ោម ៖ ទៅក្រៅហ្នឹងគេប្រើឲ្យទៅភ្ជួរស្រែ ធ្វើស្រែអីចឹងទៅណា ហើយយើងនៅចាស់យូរហើយ ងើបមិនចង់រួចគេ ។

ហៀង ៖ ចាំ! ហើយអ៊ីពេលដែលអ្នកថ្មីចូលមកហ្នឹង អ៊ីមានដឹងថាភាគច្រើនជាអ្នកណាទៅ?

ញ៉ោម ៖ អ្នកថ្មីចូលមកហ្នឹង មុនអាដេញគេឲ្យចេញហ្នឹង អ្នកថ្មីចូលមកច្រើនយូរដែរហើយ ទម្រាំខ្ញុំចេញហ្នឹង មកហើយវាចង្អៀតពេកបានគេយកពួកខ្ញុំចាកចេញហ្នឹង ដល់ចាកចេញវាឲ្យដើរធ្វើស្រែអាដេញគេហៅស្រែស្អីគេនោះ ធ្វើគ្រប់កន្លែង ។

ហៀង ៖ ចាំ! ដល់ពេលដែលអ៊ីធ្វើស្រែចឹង អ៊ីត្រូវត្រលប់មកចូលគុកគេវិញ?

ញ៉ោម ៖ អត់ទេ គេឲ្យធ្វើផ្ទះនៅក្បែរមាត់ព្រែកវិញ ។

ហៀង ៖ អូហ៍! អាហ្នឹងគេដោះលែងអ៊ីហើយមែនទេ?

ញ៉ោម ៖ អាហ្នឹងគេដូចយើងលែងហើយ ប៉ុន្តែលែងនៅក្នុងបណ្តែតបណ្តោយ នៅគ្រប់គ្រងយើងមានគេការពារនៅហ្នឹង មានគេនៅតាមទៀត ។

ហៀង ៖ តាមទៀត! ចឹងអ៊ីពេលអ្នកថ្មីចូលមក មានចាប់ចង ដាក់ច្រវាក់ដាក់គុកអីដូចគ្នា?

ញ៉ោម ៖ មកសុទ្ធតែស្គាបសេកចង រឹងក្រញ៉ង់ទាំងអស់!

ហៀង ៖ មានវ៉ៃទេអ៊ី?

ញ៉ោម ៖ វាមក អាពេលដែលយើងចេញទៅ យើងដឹងហើយ ដល់នេះគេយក ខ្ញុំលែងដឹងហើយកាលនោះគេវ៉ៃ គេមិនវ៉ៃនៅក្នុងហ្នឹងទេគេហៅទៅសួរចម្លើយ ទម្រាំតែគេវ៉ៃយើងមិនដឹងយើងមិនព្រួយើងស្រែកមិនព្រួ គេមិនធ្វើក្នុងហ្នឹងទេ ។

ហៀង ៖ អូហ៍! គេអត់ធ្វើក្នុងហ្នឹងទេ?

ញ៉ោម ៖ អត់ទេ! គេធ្វើកន្លែងគុកគេហ្នឹង គេនាំទៅទម្រាំតែស្រែកគេវ៉ៃយ៉ាងម៉េច ក៏ស្រែកមិនព្រួដែរអីមិនព្រួអ្នកនៅនេះគេមិនខ្លាច អាអ្នករើរាក់អីក្នុងនេះចឹងៗ ។ គេមិនឲ្យយើងព្រួទេ គេហៅទៅសួរឆ្ងាយៗនោះ ត្រូវគេវ៉ៃគេវ៉ៃ ប៉ុន្តែកាលនៅជាប់នៅក្នុងហ្នឹង មុនអាដេញគេឲ្យចេញទៅហ្នឹងព្រួសួរគេយកទៅសួរចម្លើយ អាហ៍គុកនៅចឹង គេសួរប្រហែលរំលងផ្ទះនោះអីចឹង ។

ពិចិត្រ ៖ ប្រហែលជាប៉ុន្មានម៉ែត្រដែរអ៊ី?

ញ៉ោម ៖ ប្រហែលជា៥០ម៉ែត្រទៅ១០០ម៉ែត្រយ៉ាងច្រើន ១០០ម៉ែត្រចុះមិនដល់ទេ ។

ពិចិត្រ ៖ ឮសម្លេងដែរ?

ញ៉ោម ៖ អើចុះឮតែអន្តុយស្លាប់ ចេះតែឮសូរសម្លេង ឮសូរដល់មកដែរហ្នឹង ។

ពិចិត្រ ៖ ពេលអុំចេញ?

ញ៉ោម ៖ នៅក្នុងហ្នឹង យាយកាលមិនទាន់យកចេញ កាលមិនទាន់ឲ្យខ្ញុំចេញ ។

ហៀង ៖ ហើយមកវិញអុំឃើញបែកឈាមអីដែរ?

ញ៉ោម ៖ ហ៊ឺ! យកមក អ្នកខ្លះមុខសុទ្ធតែក្រហម ។

ហៀង ៖ អុំមានដឹងទេថាអ្នកសួរចម្លើយហ្នឹងប៉ុន្មាននាក់ដែរ អ្នកសួរចម្លើយផ្សេង ឬអ្នកវ៉ៃផ្សេង?

ញ៉ោម ៖ អ្នកចាំនៅជិតហ្នឹង អាអ្នកសួរចម្លើយគេមានមកពីខាងស្រុកអីគេណានោះ ។

ហៀង ៖ សួរបណ្តើរ វ៉ៃបណ្តើរយ៉ាងម៉េចដែរអុំ?

ញ៉ោម ៖ សួរខុបមាថាគេចោទថាម៉េច បើយើងមិនឆ្លើយថាចឹងគេវ៉ៃហើយ ។

ហៀង ៖ គេវ៉ៃហ្នឹងអីអុំ គេយកអីវ៉ៃ ?

ញ៉ោម ៖ ដឹងគេយកអីវ៉ៃទេ ខ្ញុំមិនបានទៅឃើញដល់ទេ ប៉ុន្តែស្រែកដល់ ប៉ុន្តែយើងអន្តុយស្លាប់ ។

ពិចិត្រ ៖ សួរចម្លើយពេលហ្នឹងភាគច្រើនពេលណាអុំ ពេលយប់ឬពេលថ្ងៃ?

ញ៉ោម ៖ ពេលថ្ងៃប្រហែលជាម៉ោង១២ ជួនមិនទៀងពេលគេទេ ជួនពេលព្រឹកម៉ោង៨ម៉ោង៩ ។

ពិចត្រ ៖ មានបញ្ជីឈ្មោះមានអីដែរតើ?

ញ៉ោម ៖ គេមានបញ្ជីបស់គេ គេមាន ។

ហៀង ៖ គេមាន ប៉ុនមាននៅសល់ដែរទេ?

ញ៉ោម ៖ ហ៊ឺ! អត់ដឹងទេ រឿងអីដែលធ្វើមិនស្រួលត្រូវងាប់នៅក្នុងពេលហ្នឹងហ្នង ទាល់តែយើងមិនងាយទេរស់នៅក្នុងជំនាន់ហ្នឹងកម្រណាស់ គិតទៅមនុស្សរាប់ម៉ឺននាក់ចេញ១៦នាក់ គិតមើលទៅ វាបាន រាប់ម៉ឺនម៉ាស្រុក និយាយដូចស្រុកគិរីវង់ហ្នឹងមានម៉ាស្រុក ហើយមូលមកហ្នឹង ដល់រួចពីហ្នឹងទៅបានចេញទៅព្រះធាតុ ។

ពិចិត្រ ៖ ហើយ១៦នាក់ហ្នឹងអុំមាននៅចាំឈ្មោះដែរទេ ដែលរួចជាមួយអុំ?

ញ៉ោម ៖ អ្នករួចហ្នឹងចាំ ប៉ុន្តែឥលូវស្លាប់អស់ច្រើនហើយ នៅសល់តិច ១៦នាក់ហ្នឹងមើល តាយឹមក៏ស្លាប់ ហើយដល់បងយុនបងថ្លៃខ្ញុំក៏ស្លាប់ ហើយដល់ឈ្មោះតាទិននៅកំពែងក៏ស្លាប់ យាយអេង យាយអេងហ្នឹងដឹងនៅមិននៅផង នៅឃុំដាំប៉ែងខ្លះ ភូមិដាំប៉ែង ឃុំកំពែង

ឃុំអង្គប្រាសាទ ត្រឃុាំ ត្រឃុាំហ្នឹងមួយ អាឌុំអាឌុំហ្នឹងបានធ្វើអាដេញខាងឃុំអង្គប្រាសាទ កាលហ្នឹងនៅក្មេង តូច ។

ពិចិត្រ : គាត់ជាប់ដែរ?

ញ៉ោម : ជាប់ដែរ ជាប់ជាមួយគ្នា រួចដែរ ។

ពិចិត្រ : មូលហេតុអីបានជាប់?

ញ៉ោម : មិនដឹងគេចោទម៉េចទេ គេអត់មានឲ្យយើងដឹងទេរឿងទាំងអស់ហ្នឹង យើងអ្នកដែលនៅក្នុងហ្នឹងក៏មិនអាចសួរទៅយាយជាមួយគ្នាបានដែរ ជំនុំគ្នាមិនស្រួលផាប់សម័យហ្នឹង តាហ៊ានឃើញជំនុំគ្នាមិនស្រួលហ្នឹង ការនិយាយស្ដីសុទ្ធតែលបខ្សឹបគ្នាមិនឲ្យគេដឹងមិនឲ្យគេឮផងហើយតាកេង១ដែលខ្ញុំថាឆ្លើងឲ្យអង្គរឲ្យមាន់គេត្រង់១ហ្នឹង ដល់ក្រោពីហ្នឹងគេឆ្លើយទៅវាខុសគាត់ទាំងអស់ គាត់ឡើងមុខខ្មៅ១ខុសគេតែម្នាក់ ម៉ោងប៉ុន្មានម៉ោង៤ គេយកខ្សែមកចងត្រូវតាឯងរួច តែមុននឹងរួចគេសុំចងការពារអាយុជីវិតខ្លាចតាឯងភិតភ័យរត់ទៅ តារត់គេបាញ់ហើយគេប្រាប់ចឹង ម្ល៉ោះហើយគេចង យកទៅគេថាមុននឹងទៅជួបជុំគ្រួសារយកទៅជួយធ្វើបន្ទីរនៅកន្លែងគេហៅពោធិវ៉ា១ មួយអាទិត្យបានតៅដល់ គ្រួសារ ។

ហៀង : ពីណាគេអ្នកចាប់ចងអ្នកនិយាយប្រាប់អញ្ចឹង?

ញ៉ោម : អ្នកកាន់គុកហ្នឹង ។

ហៀង : អ្នកកាន់គុកមិនមែនអ្នកយាមនៅគុកហ្នឹងទេអុំ?

ញ៉ោម : អត់ទេអ្នកកាន់គុកហ្នឹងហ្នង អ្នកមកសួរហ្នឹងនេះទេអាហ្នឹងខាងស្អីគេហៅអ្នកអីគេទេឈ្មោះឆយ គេមកសួរទៅដល់គេចងអង្រឹងជាប់ខ្ញុំនៅលើផ្ទះហ្នឹងចងអង្រឹងហើយគេសួរគេថាចុះតា១ពូ១មានរឿងអីដែរបានជាមកជាប់ពេញហ្នឹងគេថា ខ្ញុំឃើញអញ្ចឹងខ្ញុំអាណិតដល់ហើយគេថាអញ្ចឹងណាគេថាឃើញអាណិតដល់ហើយឥលូវហ្នឹងហើយគេថា ខ្ញុំចង់សួរបើសិនជាប្រាប់ខ្ញុំត្រង់ខ្ញុំជួយដោះស្រាយបានរួច១ ។ ដល់តាហ្នឹងគាត់ឆ្លើយតាមត្រង់អញ្ចឹងទៅក៏គេថារួច១ដល់តែខ្ញុំរួចមកក៏តាហ្នឹងមិនឃើញដឹងទេឯណាទេ គេថាឲ្យទៅរៀនឲ្យនៅជួយសិនជួយចាក់បន្ទីចាក់អីសិនបានឲ្យមកជួបជុំគ្រួសារ ដល់តែមកហ្នឹងបាត់ទៅមិនឃើញមិនដឹងវាយកទៅរៀនឯណាបាត់ ។

ហៀង : អញ្ចឹងដល់ពេលអុំចប់ពីគេបញ្ជូនអុំចេញវិញមក អុំមកនៅក្នុងភូមិយើងនេះវិញ?

ញ៉ោម : មកភូមិ ។

ហៀង : ហើយអុំធ្វើអីទៅ ពេល៧៦នឹង?

ញ៉ោម ៖ ខ្ញុំគ្មានធ្វើស្អីទេ ប្រជាជន ។

ហៀង ៖ គេឲ្យធ្វើអីទៅ?

ញ៉ោម ៖ អូ! គេឲ្យធ្វើនឹងតាមគេប្រើ ពេលនឹងគេឲ្យធ្វើទូ ធ្វើកញ្ជើ ធ្វើលប ។ មុនប្រើគេឲ្យធ្វើស្រែ ម៉េចគេទេ កាលនោះគេឲ្យចាប់ដកដីស្រែ២នាក់ដែលនៅក្នុងភូមិនោះ ដែលនៅភ្នំពេញ គេធ្វើស្រែម៉េចទេ អានឹងគេឲ្យពួកខ្ញុំដើរធ្វើស្រែនឹង ។ មានក្របី មានគោគេ ឲ្យធ្វើ ។

ហៀង ៖ អ៊ំធ្វើចឹងរហូតដល់ចប់ម៉ង?

ញ៉ោម ៖ ដល់ចឹងគេធ្លាក់៧៩នឹង ពួកថ្មីចេញមក បានគេឲ្យខ្ញុំទៅនៅក្រៅ ។

ហៀង ៖ ទៅនៅណាវិញ?

ញ៉ោម ៖ នៅក្បែរមាត់បឹងក្រោម គេធ្វើផ្ទះឲ្យនៅ ប៉ុនមានអ្នកការពារនៅតាមមើលយើងចឹងដែរ ។

ហៀង ៖ គេមើលតែអ៊ី?

ញ៉ោម ៖ មើលនឹង គ្នា១៦នាក់ ។

ហៀង ៖ គ្នា១៦នាក់ ដែលថាជាប់នឹង?

ញ៉ោម ៖ ថាជាប់នឹង ។

ហៀង ៖ តែពេលអ៊ំមកវិញ គេនៅមើលអ៊ំទៀត?

ញ៉ោម ៖ ដល់រួចចេញមកផ្ទះ គេឲ្យមកវិញ គេអត់លែងតាមមើល គេបើកឲ្យយើងមានសិទ្ធិនៅតាមភូមិ ។

ហៀង ៖ ចឹងអ៊ំឡូងពេលនៅភូមិនឹង អ៊ំធ្វើការតែមិញ ដូចអ៊ំនិយាយមិញ?

ញ៉ោម ៖ បាទ!

ហៀង ៖ ធ្វើលន ធ្វើអីចឹង?

ញ៉ោម ៖ បាទ! អានឹងនៅក្នុងគេនឹង ដល់យើងរួចមកផ្ទះ ធ្វើតាមគ្រួសារយើងវិញ ។

ហៀង ៖ អ៊ំធ្វើចឹងរហូតម៉ង?

ញ៉ោម ៖ ធ្វើការដល់ពេលទៅធ្វើស្រែចឹងទៅ យើងមកពេល មកពីធ្វើស្រែវិញ គេឲ្យយើងធ្វើលប ធ្វើទូ ធ្វើកញ្ជើ តាមដែលគេត្រូវការ ។

ហៀង ៖ អ៊ំមានស្គាល់អ្នកកាន់អ៊ំទេ មេកងដែលកាន់អ៊ំ?

ញ៉ោម ៖ កងនឹងគេសុទ្ធតែនៅស្អីណា ស្គាល់ឈ្មោះមិនដឹងថាគេនៅណា ។

ហៀង ៖ ឈ្មោះអីគេ?

ញ៉ោម ៖ ឈ្មោះ ប៉ិ ព្រីង អានឹងប្រធាន ហើយនឹងប៉ិ អ៊ុម អនុប្រធាន ហើយដល់ ប៉ិស្អីណាចង់ភ្លេចឈ្មោះៗ ស្អីទៅនៅភ្នំពេញថាងាប់ដែលហើយអានឹង ធាន នៅផ្សារចាស់នឹង រួចហើយកាលបែកខ្ញុំទៅជួបម្តងហើយ ឮថាងាប់ហើយ ។

ហៀង ៖ ហើយអ៊ំមានស្គាល់គណៈឃុំ ឬមួយក៏គណៈស្រុកអីទេ? មានឮឈ្មោះ?

ញ៉ោម ៖ គណៈឃុំ ជីមិនស្គាល់ ។

ហៀង ៖ អ្នកណាគេ?

ញ៉ោម ៖ គណៈស្រុកគេ តាទិត តាតុំ តាណែនអីគេ ។

ហៀង ៖ ចុះពេលប្រជុំអ្នកភូមិអ្នកស្រុក អ៊ំដែលឃើញពួកគាត់មកទេ?

ញ៉ោម ៖ ទេ! តែប្រជុំមក ។

ហៀង ៖ ពីណាមក?

ញ៉ោម ៖ យាយបូ តាតុំ តាណែន ។

ហៀង ៖ មកប្រជុំជាមួយគ្នាអីទៅ ជាមួយអ្នកភូមិ?

ញ៉ោម ៖ បាទ!

ហៀង ៖ គាត់និយាយអីខ្លះ?

ញ៉ោម ៖ ធម្មតាម៉ាឃុំគោកព្រេចគេយកទៅប្រជុំនៅរាមអណ្តើក គេឲ្យយើងទៅទាំងអស់គ្នា ទៅណាដាក់ ។

ហៀង ៖ គេខស្សប្រាប់ប្រជុំ?

ញ៉ោម ៖ ហ៊ឺ! ប្រជុំគេដូចថាប្រជុំរួមស្រុកគេ យូរៗម្តង ។

ហៀង ៖ យូរៗម្តង ម៉ាខែម្តង ម៉េចដែរ?

ញ៉ោម ៖ ទេ! មិនម៉ាខែទេ ជួន២ខែ ហើយក៏យ៉ាងយឺតណាស់ក៏ម៉ាខែ ។

ហៀង ៖ ហើយចុះប្រជុំភាគច្រើនគេនិយាយអី?

ញ៉ោម ៖ គេនិយាយពីសុទ្ធតែរឿងចលនាធ្វើស្រែធ្វើចំការអីគេម៉េចបានផល ធ្វើម៉េចរែកប្រឡាយដាក់ទឹកប្រឡាយ ជីកប្រឡាយទំនប់អីនឹង ។

ហៀង ៖ អត់មាននិយាយអីផ្សេងពីនឹង?

ញ៉ោម ៖ អត់មាន ការណែនាំរឿងធ្វើមានតែរឿងនឹងមួយ បើការរឿងផ្សេងសម្រេច គេម៉េចឲ្យយើងដឹង ។

ហៀង ៖ ភាគច្រើនប្រជុំយូរ ប៉ុន្មានម៉ោង?

ញ៉ោម : ប្រជុំគេ ម៉ាម៉ោង២ម៉ោង ជួនកាលការងារគេតិចច្រើន ។

ពិចិត្រ : ពីណាគេ អ្នកនិយាយដែលនៅក្នុងអង្គប្រជុំនឹង?

ញ៉ោម : អង្គប្រជុំនឹងមានគណៈស្រុកគេ ។

ពិចិត្រ : អ៊ំមានស្គាល់ឈ្មោះទេ?

ញ៉ោម : យាយបូនឹង ស្រី ។

ពិចិត្រ : គាត់អ្នកនិយាយ?

ញ៉ោម : អឺ!

ពិចិត្រ : ហើយអ៊ំម៉េចដឹងថាគាត់ឈ្មោះយាយបូ?

ញ៉ោម : អ្នកស្រុកអ្នកភូមិគេស្គាល់អស់ ។

ជាតិ : តាទិត ឈ្មោះអីទិត?

ញ៉ោម : អីទិត មិនដឹងអីទិត តាទិតនឹងគាត់មកប្រជុំនឹង ដឹងតែឈ្មោះអី ។

ជាតិ : ហើយតាគុំមុនតាទិត ឬមួយតាទិតមុនតាគុំ?

ញ៉ោម : តាទិតនឹងធំជាងតាគុំ ។

ជាតិ : តែមិនមែនបងប្អូនគ្នា?

ញ៉ោម : អត់ដឹង មិនដឹងជាបងប្អូន សុទ្ធមកពីឆ្ងាយ សុទ្ធតែត្រាំកក់ គេសុទ្ធតែ១០៥ យើងនេះ ១០៩ វាគ្មានដាក់ស្រុកគិរីវង់ ស្រុកនេះចេះចុះ ១០៨ ១០៦ ១០៩ ។

ជាតិ : ៧៨អី គេមានជម្លៀសប្រជាជនពីគិរីវង់ទៅត្រាំកក់?

ញ៉ោម : ហ៎! កាល៧៨ គេឲ្យយើងជម្លៀសទៅកោះអណ្ដែកនេះ ។ ពួកថ្មីគេបញ្ជូនទៅលើចេះ ។

ជាតិ : លើនឹងខាងណា?

ញ៉ោម : ទៅលើខាងត្រាំកក់ អានឹងគេហៅលើទៅលើ ។

ជាតិ : ម៉េចចឹង?

ញ៉ោម : មិនដឹងម៉េចទេ ពួកអ្នកនៅមូលដ្ឋានគេឲ្យទៅនៅត្រាំកក់ដដែល អ្នកនៅមូលដ្ឋាន អ្នកដែលមកថ្មីដែលចេញពីភ្នំពេញមក ហៅថ្មី អានឹងគេទៅលើចេះ ទៅត្រាំកក់ទៅអី ១០៥ ។

ពិចិត្រ : ចង់បកក្រោយតិច ទាក់ទងនឹងរឿងគុក ថាអ្នកយាមគេមានប៉ុន្មាននាក់ដែរ មានដឹង?

ញ៉ោម : អ្នកយាមឈ្លប ជួនគេយកឈ្លបឃុំមកការពារផង ជួនអ្នកនៅក្នុងនឹងប៉ុន្មាន អ្នកនៅប្រចាំការណ៍ជាប់តែ៣នាក់ទេ ។ ប្រចាំការណ៍គេប្រធាននៅនឹង ហើយគេធ្វើការអ្នកតាមដូចថា

ឈ្លបឃុំអី គេមកការពារនៅក្បែរៗនឹង ជិតៗនឹង បើមានការអី គេទាក់ទងជិតៗបង្កើយ ជំនួយការ ។

ពិចិត្រ : ចុះអ្នកយាមដូចគុកដែលអ៊ំជាប់ផ្ទាល់មាន?

ញ៉ៅម : មានអ្នកប៉ុន្មាននាក់នឹង ដែលប្រធានគុកនឹង ២-៤នាក់នឹង ។

ពិចិត្រ : ចុះអត់មានអ្នកយាមច្រើនផ្សេងទៀតទេ?

ញ៉ៅម : អត់ទេ មានតែឈ្លបនឹង ជួនគេទៅនៅនឹងម៉ាថ្ងៃ២ថ្ងៃ គេនៅតាមភូមិក្បែរៗនឹងដែរ មានកិច្ចការអីៗ គេទាក់ទងគ្នា ។ ដល់មនុស្សមកច្រើន ពួកឈ្លប មកស្កុបស្កះពេញទឹកពេញដីទាំងអស់នឹង ។ អ្នកបញ្ជូនមកចេះបញ្ជូនមក មកសុទ្ធតែប្រដាប់គេ មកគេបញ្ជូនមកម្តង ៣-៤-៥នាក់ សុទ្ធតែចងខ្សែដោតជន្លាសទៀត ។

ហៀង : ដោតជន្លាសម៉េច?

ញ៉ៅម : ចងសេកចឹង ហើយដោត ថា១០នាក់ចឹង គេបង្ហូតខ្សែទាំងនេះនឹងជាប់គ្នាទាំង១០នឹង គេចងបង្ហូតជាប់គ្នា គ្មានឲ្យយើងជាប់តែមួយៗទេ ។

ហៀង : ខ្សែនឹងខ្សែអី ខ្សែពួរ?

ញ៉ៅម : ខ្សែយើងខ្សែដក់ត្នោត អាខ្សែគោនឹង ។

ពិចិត្រ : ចុះអ៊ំពេលអ៊ំចេញមក គុកនឹងរំសាយ?

ញ៉ៅម : កាលខ្ញុំចេញមក គេរំសាយ រុះទៅនោះ ។

ពិចិត្រ : ហើយចុះអ្នកនៅក្នុងគុកនឹង?

ញ៉ៅម : អ្នកនៅក្នុងគុកគេនៅសល់ខ្លះគេបញ្ជូនទៅនឹង ។

ពិចិត្រ : នៅដល់ប្រហែលប៉ុន្មាន ពេលអ៊ំចេញមក?

ញ៉ៅម : ចេញមក ខ្ញុំចេះគេឲ្យចេញទៅនៅក្រៅហើយ ដល់សល់ពីរុះទៅខ្ញុំមិនដឹងដែរ ។

ពិចិត្រ : ចុះអ៊ំមានដឹងថាគេបញ្ជូនអ្នកដែលនៅសល់ពីគុកនឹង ទៅគុកវត្តព្រះធាតុនឹងពេលណា?

ញ៉ៅម : ខ្ញុំនៅក្រៅដឹងដែរ ប៉ុនខ្ញុំមិនដឹងគេបញ្ជូនទៅបានប៉ុន្មាននាក់ គុកនឹងកាលនៅនេះ ខ្ញុំរួចចេញមកហើយបានបញ្ជូនទៅ ។

ពិចិត្រ : ពេលអ៊ំរួចចេញមកហើយ បានគេរំសាយ?

ញ៉ៅម : គេរុះយកទៅនោះមិនបានយូរទេ យ៉ាងយូរម៉ាឆ្នាំប៉ុននឹង ។

ពិចិត្រ : ម៉ាឆ្នាំក្រោយពីអ៊ំចេញ?

ញ៉ៅម : ក្រោយពីកន្លែងខ្ញុំចេញ ។

ពិចិត្រ ៖ ចុះអ៊ំម៉េចដឹងគេរំសាយគុកនឹង?

ញ៉ោម ៖ អឺ! ចុះបើអ្នកស្រុកអ្នកភូមិគេថា គ្រាន់ដឹងយកទៅនឹង ។

ពិចិត្រ ៖ ចុះអ៊ំមានធ្លាប់ទៅមើលគុកនឹងវិញអត់ ពេលក្រោយដែលអ៊ំចេញហើយ?

ញ៉ោម ៖ ដល់នេះគេរុះចោលវិញអស់ ។

ពិចិត្រ ៖ អត់មានសល់ស្នាកស្នាមអីទៀតទេ?

ញ៉ោម ៖ គេយកទៅអស់ ។

ហៀង ៖ ចឹងអ៊ំពេលដែលគុកអ៊ំនៅនឹង ពេលគេរំសាយនឹង គុកព្រះធាតុនឹងកើតនៅ?

ញ៉ោម ៖ គេធ្វើនោះហើយ បានគេបញ្ជូននេះទៅ ។

ហៀង ៖ នៅឆ្នាំណាដែរអ៊ំចាំទេ?

ញ៉ោម ៖ កាលខ្ញុំរួចវា៧៦ ដើម៧៦ ។

ហៀង ៖ ដើម៧៦?

ញ៉ោម ៖ អឺ!

ហៀង ៖ ចឹងប្រហែលជាដើម៧៦បានគេរើទៅ?

ញ៉ោម ៖ បាទ! ដើម៧៦នឹងគេធ្វើហើយ ប៉ុនវាមិនទាន់ហើយ ដល់គេប្រហែលជាក្នុង៧៦នឹងដែរ បែបគេបញ្ជូនទៅ ។ ប្រហែលជាចុង៧៦នឹងបានគេនាំបញ្ជូនទៅ ។

ហៀង ៖ ចុះអ៊ំអំឡុងពេលដែលអ៊ំនៅគុកចាស់នឹង អំឡុងពេលនឹងមានអ្នកទោសចេញចូលច្រើននាក់?

ញ៉ោម ៖ ហ៎! ដល់អ្នកចេញមក គេរុះទង់ជ័យបាត់អស់ គេរុះចោលអស់ ។

ហៀង ៖ តែអំឡុងពេល៣ឆ្នាំ នៅក្នុងគុកនឹង មានអ្នកទោសចេញចូលច្រើន?

ញ៉ោម ៖ អ្នកទោសដូចខ្ញុំថាចឹង រាប់ម៉ឺននាក់នៅដល់ ហើយដល់ពេលវាចូលច្រើនពេក វាយកខ្ញុំចាស់យកចេញទៅនៅ ។

ហៀង ៖ មិញគុកដែលអ៊ំជាប់ម៉ាខែជាងនឹង គុកឈ្មោះអីគេ?

ញ៉ោម ៖ ខែអានឹងគេយកទៅ ឃុំគេចាប់ យកទៅសំរោងកើតនោះ ។

ហៀង ៖ កន្លែងណាដែរអ៊ំ?

ញ៉ោម ៖ សំរោងកើតនៅហួសវត្តចំបក់នេះទៅបៀតមណ្ឌល ។

ហៀង ៖ ប៉ុន្តែនៅសំរោងកើតនឹង អ៊ំនៅកន្លែងណា នៅផ្ទះ ឬម៉េច?

ញ៉ោម ៖ នៅផ្ទះគេ ។

ហៀង : ផ្ទះនឹងម៉េចទៅ មានប្រវ៉ាក់?

ញ៉ោម : ផ្ទះនឹង អ្នកស្រុកគេចងដូចខ្ញុំថាចឹង ដូចអ្នកនៅជាមួយ ខ្ញុំនឹងគេលែងសុទ្ធតែចំណង ។

ហៀង : នៅបានម៉ាខែជាង បានគេប្តូរមកគុកនេះវិញ?

ញ៉ោម : ម៉ាខែ៤ថ្ងៃ ។

ហៀង : ម៉ាខែ៤ថ្ងៃបានគេបញ្ជូនអ៊ំមកគុកនេះ?

ញ៉ោម : បានបញ្ជូនមកនេះ គេបញ្ជូននឹងមិនដឹងថាគេបញ្ជូនមកនឹងផង ។ ថ្ងៃល្ងាចម៉ោង៤ម៉ោង៥ នឹង ស្រូវបែកគុម្ពចឹង គេថ្ងៃនឹងមួយមិនដឹងម៉េចគេយកក-គោមួយ យកមកគេដាំបាយ ស្រួយឲ្យស៊ីៗ មិនដឹងគេបញ្ជូនមកនឹង គេខ្លាចដើរអត់រួច ឲ្យហូបម៉ាឆ្អែត ។

ហៀង : គេបញ្ជូនមកគេឲ្យអ៊ំដើរ?

ញ៉ោម : បាទ!

ហៀង : ចឹងមុនគេបញ្ជូនចេញពីគុកនៅសំរោងកើត?

ញ៉ោម : ផ្ទះ ។

ហៀង : ចឹងមុននឹងគេបញ្ជូនឲ្យអ៊ំមក គេឲ្យអ៊ំហូបឲ្យឆ្អែតសិន?

ញ៉ោម : ហូបឲ្យឆ្អែតសិន ហើយដល់មកពីនឹងមានតែ៧នាក់ទេ ។

ហៀង : ចេញពីនោះមកតែ៧នាក់ទេ អ្នកជាប់នៅនឹង?

ញ៉ោម : បាទ!

ហៀង : ភាគច្រើន ពីណាគេអ្នកចាប់មក សុទ្ធតែពួកឃុំ?

ញ៉ោម : អានឹងសុទ្ធតែពួកឃុំបញ្ជូន ។

ហៀង : ឃុំគេចាប់ដាក់នឹង ហើយមានប្រហែល៧នាក់ ។ ពេលបញ្ជូនមកនឹងគេឲ្យដើរ?

ញ៉ោម : ដើរ ។

ហៀង : ដើរគេមានចង?

ញ៉ោម : ចង ហើយដោតជន្ទាសដូចខ្ញុំថាចឹង ។ ចងតឹងហើយ គេដោតខ្សែនឹងជាប់គ្នា ។ ហើយ អាការគេ២ដើមនៅអមសងខាងចឹង ។

ហៀង : ពួកវាដើរត្រសៀរយើង ឬមួយដើរពីមុខពីក្រោយ?

ញ៉ោម : ដើរពីក្រោយយើង ឲ្យយើងដើរពីមុខ ។

ហៀង : ចុះមានអ្នកនាំមុខដើរ?

ញ៉ោម : អត់ទេ គេគ្រាន់ប្រាប់តាមផ្លូវទៅនេះៗ ។

ហៀង ៖ ចឹងប៉ុន្មាននាក់ៗ?

ញ៉ោម ៖ អ្នកបញ្ជូនមកនឹង២នាក់ ប៉ុនកាំភ្លើង២ដើម... គេភ្ជង់ពីក្រោយ ។

ហៀង ៖ ចុះ២នាក់នឹងនៅពីក្រោយទាំងពីរ?

ញ៉ោម ៖ នៅទាំងពីរ ។

ហៀង ៖ ហើយអត់មានអ្នកណាគេហ៊ានរើបំរាស់?

ញ៉ោម ៖ ហ៎! ហ៊ានៗបាញ់ប្រាវ ។ រើ មិនដឹងរើម៉េច នៅក-ដៃ គល់ដៃនេះផង ចុងដៃនេះផង ហើយអាខ្សែដោតជន្ទាសជាប់គ្នា ។

ហៀង ៖ ដើររហូតមកដល់?

ញ៉ោម ៖ តាំងពីសំរោងកើតមកៗចូលនៅគុកនេះ ។

ហៀង ៖ គុកអីគេ?

ញ៉ោម ៖ ក្រាំងស្វាយនេះ ។

ហៀង ៖ គុកក្រាំងស្វាយនឹងកើតតាំងពីឆ្នាំណា?

ញ៉ោម ៖ ឆ្នាំ៧៣នឹង ចូលនៅមុនដំបូងគ្នា៧នាក់នឹងថ្មីចេស ។

ហៀង ៖ ចឹងអ៊ំអ្នកសម្ពោធន៍គុកនឹងមុនគេ នៅឆ្នាំ៧៣?

ញ៉ោម ៖ សម្ពោធន៍មុនគេ គេហៅថ្មីចេសចូលម៉ង ៧៣ ។

ហៀង ៖ ពេលអ៊ំចូលទៅដល់ភ្លាមគេសួរចម្លើយភ្លាម ម៉ង ឬមួយគេទុកប៉ុន្មានថ្ងៃសិន?

ញ៉ោម ៖ ចម្លើយនោះ គេសួរតាំងនៅឃុំនោះហើយ ដល់ឡើងមកនេះ បានម៉ាថ្ងៃ២ បានកន្លែងនេះគេសួរ ។

ហៀង ៖ អ្នកនៅនឹងប្រហែលជាប៉ុន្មាននាក់ដែរ?

ញ៉ោម ៖ អ្នកដែលចូលមកដំបូងនោះ?

ហៀង ៖ អ្នកយាមៗ ។

ញ៉ោម ៖ អ្នកយាមគេដូចខ្ញុំប្រាប់ មានប៉ុន្មាន៣-៤នាក់ នឹងគេអ្នកនៅនឹង ហើយបើឈ្លបគេដើរចេញចូល បញ្ជូនមនុស្សចេញចូលគ្នាគេច្រើន៣-៤-១០នាក់ ។

ហៀង ៖ អ៊ំនៅចាំពេល៧៥ គេជម្លៀសពីភ្នំពេញមក គេមានបញ្ជូនចូលនៅក្នុងគុកក្រាំងស្វាយនឹង គេបញ្ជូនមកអាចច្រើន អាចដល់ប៉ុន្មានរយនាក់ទៅ អាចចាំ អាចស្មានបានទេ?

ញ៉ោម ៖ មនុស្សម៉ាស្រុក យើងនិយាយពីម៉ាស្រុក១០៩ ពីដើមកាលនឹងគេនិយាយចឹង ។ ចុះមកគ្រប់ឃុំ មកតាំងពីឃុំព្រៃរំដេង ឃុំសោម ឃុំចាអួរ ឃុំរាមអណ្ដើក ឃុំអីមកគ្រប់ម៉ាស្រុកគីរីវង់ ។

ហៀង ៖ ចឹងដូចគុកស្រុក?

ញ៉ោម ៖ អានឹងម៉ាស្រុកគេ ។

ហៀង ៖ ចឹងពេលអ៊ំនៅក្នុងគុកស្រុកនឹង ពេលឆ្នាំ៧៥ប្រហែលខែប៉ុន្មានគេឲ្យអ៊ំចេញក្រៅ ហើយដាក់អ្នកថ្មីចូល?

ញ៉ោម ៖ អានឹង៧៦ បានខ្ញុំចេញ ។

ហៀង ៖ ៧៦បានអ៊ំចេញ ពេលមិនទាន់អ៊ំចេញ អ៊ំនៅធ្វើស្រែឲ្យពួកវាសិន?

ញ៉ោម ៖ ហ្នឹងហើយចេញមុនដំបូងនៅក្នុងនឹង ៧៥នឹង ប្រហែលជាជិតដាច់៧៥ បានឲ្យចេញ ។

ហៀង ៖ ប្រហែលជាខែ?

ញ៉ោម ៖ ខែ១១ ១២ ខ្ញុំចេញក្រៅបាន៣ខែទៀត ទាំងអស់វា១៨ខែ ខ្ញុំរួច៧៦ខែ៣ ។ បានរួច ។

ហៀង ៖ ៧៦ខែ៣បានអ៊ំបានមកស្រុកវិញ?

ញ៉ោម ៖ បាទ! ១៨ខែ គិតមើលដើមចុង៧៣វា៣ខែ ហើយដល់ពេញម៉ាឆ្នាំ៧៥នឹង វា១២ខែ ហើយ៦ខែវា១៨ខែ ។

ហៀង ៖ ចឹងដល់ពេលចេញមកហើយអ៊ំអត់ដឹងរឿងអីទៀត ទាក់ទងនឹងគុកនឹងទៀតទេ?

ញ៉ោម ៖ អឺ! គ្រាន់បានចេញហើយមិនហ៊ានទៅជិត ។

ហៀង ៖ អត់មានខ្វល់រឿងនឹងទៀត?

ញ៉ោម ៖ មិនខ្វល់ទេ ខ្លាចជៀសមិនហ៊ានចង់ ។

ហៀង ៖ ចឹងអ៊ំឮតាមអ្នកណាគេដែរ ថាមានគេរើពីគុកក្រាំងស្វាយហើយទៅគុកព្រះធាតុ?

ញ៉ោម ៖ ហ្នឹងហើយរើនឹង ខ្ញុំចេញហើយអានឹងបានគេរើ ។

ពិចិត្រ ៖ ម៉េចដឹងគេរើ អ៊ំដឹងតាមពីណា?

ញ៉ោម ៖ ដឹង អ្នកភូមិគេដឹងគ្រប់គ្នា ។

ពិចិត្រ ៖ អ្នកភូមិណា?

ញ៉ោម ៖ ភូមិនឹង បើមនុស្សចេញចូលចន្លោះនឹង ដល់នឹងគេលែងយកបញ្ចូលទៅនឹង ដឹងថាគេបញ្ជូនទៅនោះ បញ្ជូនទៅក្រោម ។

ពិចិត្រ ៖ ដល់ពេលអ៊ំដឹងថាគេប្តូរពីក្រាំងស្វាយទៅព្រះធាតុនឹង អ៊ំមានដែលទៅមើលទីតាំងគុកចាស់នឹងទេ?

ញ៉ោម ៖ ហ៊ឺ! អត់ហ៊ានទៅជិតទេ ។

ពិចិត្រ ៖ ចុះមកដល់ឥឡូវនោះ ទីតាំងគុកចាស់ក្រាំងស្វាយនឹង?

ញ៉ោម ៖ ឥឡូវលែងអីហើយ ឥឡូវអត់មានអី ។

ពិចិត្រ ៖ ក្លាយជាអីវិញ វាលស្រែ ឬក្លាយជាអី?

ញ៉ោម ៖ ចំការ ដាំទូលធ្លាប់ភូមិចាស់ពីដើម ។

ពិចិត្រ ៖ ចឹងពេលអ៊ំត្រឡប់ចេញពីគុកហើយឆ្នាំ៧៦ អ៊ំនៅក្នុងភូមិនឹងវិញដដែល គោកព្រេចនឹង?

ញ៉ោម ៖ នៅក្នុងភូមិនឹងដដែល ។

ពិចិត្រ ៖ ហើយនប្រធានសហករណ៍គោកព្រេចនឹង ឈ្មោះអី អ៊ំមានស្គាល់ទេ?

ញ៉ោម ៖ ប្រធានសហករណ៍គោកព្រេចកាលនោះ ។

ហៀង ៖ បាទ! កាលសម័យខ្មែរក្រហមនឹង ។

ញ៉ោម ៖ ប្រធានសហករណ៍ ប្រធានភូមិកាលនឹង ស្លាប់អស់ហើយ ។

ហៀង ៖ គាត់ឈ្មោះអីគេ?

ញ៉ោម ៖ ខ្វរអីនឹង ស្លាប់អស់ហើយ អានឹងប្រធានភូមិ ។ ពួកនឹងកាលបញ្ជូនទៅកោះអណ្តែតនឹងគេយកគ្នាវៃចោល វៃបន្ត ។

ពិចិត្រ ៖ បញ្ជូនទៅកោះអណ្តែតពេលណាអ៊ំ?

ញ៉ោម ៖ បញ្ជូនទៅកោះអណ្តែត៧៩យើងរត់ ទៅ៧៨ អានោះ ។

ពិចិត្រ ៖ ពីណាគេវៃ?

ញ៉ោម ៖ មិនដឹង ។

ពិចិត្រ ៖ ខាងខ្មែរក្រហម ឬខាងណា?

ញ៉ោម ៖ ខាងខ្មែរក្រហមគេចោទខុសចេះខុសចុះគ្នាវានឹង ។

ពិចិត្រ ៖ ហើយយកទៅវៃចោល?

ញ៉ោម ៖ ដឹងយកទៅវៃណា ។

ពិចិត្រ ៖ ចុះអ៊ំម៉េចដឹង?

ញ៉ោម ៖ ទៅបាត់មនុស្ស ។

ពិចិត្រ ៖ ពួអ្នកភូមិនិយាយ ឬក៏អ៊ំ?

ញ៉ោម ៖ អ្នកភូមិមិនមាន មិនដឹងតាមយើងមិនហ៊ានទៅជួបគេទេ.... ។

ពិចិត្រ ៖ ចុះដល់ពេលវៀតណាមចូលមក វៀតណាមចូលឆ្នាំ៧០ប៉ុន្មាន?

ញ៉ោម ៖ ៧៩ ។

ពិចិត្រ ៖ អ៊ំមានរត់ទៅលើដូចគេដែរ?

ញ៉ោម ៖ ពួកខ្ញុំដល់ទៅនរាយណ៍ ។

ពិចិត្រ ៖ នរាយណ៍នៅខាងណា?

ញ៉ោម ៖ នរាយណ៍ស្រុកត្រាំកក់ ។

ពិចិត្រ ៖ ខេត្តតាកែវដែរ?

ញ៉ោម ៖ ខេត្តតាកែវ ។

ពិចិត្រ ៖ ចឹងរត់ទៅប៉ុន្មានជាមួយអ្នកណាគេខ្លះ?

ញ៉ោម ៖ អឺ! មនុស្សមកម៉ាស្រុក ទៅនឹងទាំងអស់ ។

ពិចិត្រ ៖ ទាំងខ្មែរក្រហមទាំងអីរត់ទៅជាមួយគ្នា?

ញ៉ោម ៖ រត់ទៅ ។

ហៀង ៖ ទាំងទ័ពទាំងអីដែរ?

ញ៉ោម ៖ រត់ទៅទាំងទ័ពទាំងអីនឹង ទៅគេបេះរុញទៅ ។

ហៀង ៖ ពីណារុញទៅ?

ញ៉ោម ៖ ពួកអាឈ្លបគេនេះនឹង គេបេះតែឡូទៅៗ គេនៅបណ្ដេញទៅរហូត ។ ហើយដល់ខ្ញុំអ្នកនេះនឹងមិនចង់ទៅបេះតែគេចៗ ។

ហៀង ៖ អ៊ំសាកនិយាយរៀបរាប់ទិដ្ឋភាពនឹង អ៊ំមានឃើញអីគេខ្លះតាមផ្លូវនឹង មានមនុស្សស្លាប់ឬក៏ម៉េច?

ញ៉ោម ៖ ហ៎! កាលទៅនឹង ទៅរកចាស់ៗ ។

ហៀង ៖ បាយហូបចុកម៉េចដែរ?

ញ៉ោម ៖ ហូបចុកអានឹងតាមដែលរត់ទៅចឹង ហូបចុកដល់ពេលរត់ទៅ កាលនឹងខែស្រូវទុំយើងមានរទេះមានគោបរទៅៗដល់ណាស្រូវមានដល់ណាច្រូតបុកហូបខ្លួនឯងរត់ទៅ អានឹងបានហូបឆ្អែតហើយ ហូបខ្លួនឯង ។

ពិចិត្រ៖ ចុះមុនរួចចេញពីគុកហូបម៉េចទៅ?

ញ៉ោម ៖ ប្រជាជននៅតាមសហករណ៍ ។

ពិចិត្រ : ហូបម៉េចទៅអ៊ី?

ញ៉ោម : អឺ! លែងម៉ាខ្ទះ៨កំប៉ុង បាយ ។

ពិចិត្រ : គ្នាប៉ុន្មាននាក់?

ញ៉ោម : ម៉ាភូមិនឹងគេលែង នៅម៉ាភូមិនឹងគេឲ្យហូបម្តុំ ហូបបាយគេធ្វើនៅនេះ ។

ហៀង : នៅជិតនឹង?

ញ៉ោម : អឺ! កន្លែងនឹងត្រង់ ។

ហៀង : ហូបចុកគ្រប់គ្រាន់ទេ?

ញ៉ោម : អឺ!ហូបម៉េចគ្រប់ អាវែកត្រឡោកនឹងម្នាក់៣វែក បើតាមការបាយមានប្រហែលរកកន្ទះចានល្ពៅ ។

ហៀង : ចុះអ៊ំនៅតាមផ្លូវ ដែលអ៊ំជម្លៀសពេលវៀតណាមចូលមក ទៅនៅខាងណា?

ញ៉ោម : នៅត្រាំកក់ នៅនរាយណ៍ ។

ហៀង : នៅតាមផ្លូវនៅនរាយណ៍នឹង អ៊ំមានឃើញទិដ្ឋភាពអីខ្លះ មានឃើញទ័ពបាញ់គេ ឬមួយក៏ប្រជាជនម៉េចដែរ?

ញ៉ោម : ទៅនោះគេខាងនោះគេទៅបន្តពីមុខទៀត ហើយយើងពីក្រោយចេះទៅបន្តៗគ្នា ។

ហៀង : មានអ្នកស្លាប់តាមផ្លូវទៅ?

ញ៉ោម : មានឃើញដែរ ចាស់ៗទៅតាមជាមួយខ្លះបោរចោល គ្មានឃើញគាត់ដើរមិនរួចអី មានពេញតែផ្លូវកាលនឹង ។

ហៀង : ចុះក្មេងៗម៉េចទៅ?

ញ៉ោម : ក្មេងៗខ្លះតាមវង្វង់គ្រួសារទៅគេគ្រប់គ្រង គេដឹកនាំរបស់គេ ដឹកបរទេះអីទៅ ។

ហៀង : អ៊ំមានឃើញស្ត្រីមានផ្ទៃពោះដើរតាមនឹង?

ញ៉ោម : មាន ។

ហៀង : មានកើត ឆ្លងទន្លេពេលនឹង?

ញ៉ោម : មានដែរ ប៉ុន្តែមិនសូវមានទេ កាលនឹងមានតិចណាស់ ព្រោះមនុស្សគាំស្គមអស់ហើយមិនសូវមាន ។

ហៀង : ចុះអ៊ំនៅនរាយណ៍ប្រហែលបានប៉ុន្មានខែ បានអ៊ំត្រឡប់មកវិញ?

ញ៉ោម : មិនបានប៉ុន្មានខែទេកាលនឹង នៅបាន២-៣ថ្ងៃចឹងទៅគេដេញខ្លាំងពេកទៅម៉ាកិលៗ គេខានដេញ ថយមកវិញចេះមក រកតែផ្លូវវិលវិញ ។

ហៀង ៖ អ៊ំដឹងថាទៅមុខទៅអត់រួច?

ញ៉ោម ៖ ទៅមុខមានពួកខាងទ័ពគេប្រាប់ដែរ ថាទៅមុខទៅស៊ីស្អីស៊ីគល់ព្រេចអី គេអ្នកខាងទ័ពពួកខាងទ័ពប្រាប់ទំទៅមុខធ្វើអី បានជាមិនចង់ទៅ ។

ពិចិត្រ ៖ ខាងទ័ពអ្នកប្រាប់អ៊ីវិញ?

ញ៉ោម ៖ អឺ! ខាងទ័ពគេប្រាប់ ។

ហៀង ៖ ក្រែងទ័ពអាពតចង់ឲ្យយើងទៅមុខ?

ញ៉ោម ៖ អត់ចង់ឲ្យទៅទេ ខូចតែពួកឈ្លប ពួកឃុំទេ អ្នកដេញ ពួកទ័ពគេប្រាប់ ។

ពិចិត្រ ៖ ចឹងពួកឈ្លបអ្នកឲ្យទៅមុខ ប៉ុន្តែពួកទ័ពប្រាប់ឲ្យយើងបកក្រោយវិញ?

ញ៉ោម ៖ ទ័ពថាទៅមុខទៅស៊ីស្អី គ្មានអីទេទៅលើវិញ ស្រុកលើនឹងគ្មានស៊ីទេ ។

ពិចិត្រ ៖ ដល់ពេលចេញមកបានប្រហែលប៉ុន្មានខែ បានមកនេះមកដល់ភូមិវិញ?

ញ៉ោម ៖ ចេញមកនឹង មកទៅយូរដល់ពេលនេះវៀតណាមចូលដល់គេបើកជូនវៀតណាម គេបណ្ដេញឲ្យមកៗ ។

ហៀង ៖ មកជួបជាមួយវៀតណាមវិញ?

ញ៉ោម ៖ មកជួប ។

ហៀង ៖ ពេលអ៊ំទៅដល់នរាយណ៍នៅ?

ញ៉ោម ៖ ដល់នរាយណ៍ជួបនឹង ឡានអីទៅទាន់នៅនឹង ដល់ទាន់ទៅមុខបកក្រោយវិញចេះវិញ ។

ហៀង ៖ អ៊ំបកមកក្រោយជាមួយគ្រួសារមកផ្ទះ?

ញ៉ោម ៖ បកមកក្រោយ ឃើញរទេះគោ បកមកអាខ្លះណាផ្ទុះមីនក៏ផ្ទុះខាងលិចនេះណាងាប់ ។

ហៀង ៖ ផ្ទុះមីន?

ញ៉ោម ៖ ចុះកាលនឹងអាពតមិនដាក់មីន ដាក់អី ។

ហៀង ៖ អ្នកណាគេអ្នកផ្ទុះ ប្រជាជន?

ញ៉ោម ៖ ប្រជាជន ផ្ទុះ ។

ហៀង ៖ ស្លាប់ច្រើន?

ញ៉ោម ៖ មានស្លាប់មានអីគគោក ខ្លះណាទៅដើរគៀរនឹងផ្លូវខ្លះទៅដើរទាក់អាមីននឹង ស្លាប់ក៏មានរទេះមួយនៅខាងលិចស្ពាន លេងរទេះមួយហើរបាត់ ផ្ទុះមីន ។

ហៀង ៖ វាដាក់មីងនៅជាប់ជិតៗនឹង?

ញ៉ោម ៖ មីនវាដាច់ចេះ នៅផ្លូវចឹង វាដាក់ត្រង់នេះ ដាក់នេះខ្វែងគ្នាចឹង ។

ហៀង : ដាក់នៅជិតៗនឹង វាអត់នៅក្នុងព្រៃ?

ញ៉ោម : ដាក់តាមផ្លូវ ប៉ុនគេអ្នកដើរមើលមុន គេដឹងគេដើរឈ្លបមិនឲ្យ មានគេដឹងផ្នែកខាងទ័ពវៀតណាមៗ គេដឹង ហើយមានរទេះបរអត់ឲ្យខុសដើងគ្នាទេ អ្នកណាទៅតាមណាទៅតាមនឹងរហូតៗ

ហៀង : ចឹងបរនៅតាមស្នាមរទេះនឹងទៅ?

ញ៉ោម : តាមស្នាមរទេះរហូតៗ

ហៀង : តែអត់បរតាមស្នាម អាចជាន់មីន?

ញ៉ោម : ជាន់មីនៗ

ហៀង : ចឹងពេលអ៊ំមកដល់វិញ អ៊ំមករកផ្ទះខ្លួនឯងវិញចឹងទៅ?

ញ៉ោម : មករកផ្ទះខ្លួនឯងៗ

ហៀង : ហើយអ៊ំពេលនឹងមកដល់ផ្ទះមានសល់អី?

ញ៉ោម : កាលមកពីនោះមក ខ្ញុំគេឲ្យទៅនៅកោះអណ្តែតនោះនឹងៗ កាលមកពួកកម្ពុជាក្រោមគេឲ្យទៅនៅតាមភូមិយើងៗ ដល់មកចេះរកកន្លែងនៅធ្វើកន្លែងអីទៅៗ ចុះផ្ទះខ្ញុំកាលនោះគេរុះយកកាលនឹងអស់ ផ្ទះភូមិថ្មីគេរុះយកអស់រលីង ម៉ាភូមិនឹងគ្មានសល់មួយទេៗ

ហៀង : គេរុះយកផ្ទះទាំងអស់?

ញ៉ោម : រុះយកទាំងអស់ៗ

ហៀង : អ៊ំមានសល់រូបថតចាស់ៗពីជំនាន់នឹង?

ញ៉ោម : ចាស់ៗគ្មានៗ

ហៀង : ស្អីក៏អត់មាន អនុស្សាវរីយ៍កាលពីជំនាន់អត់មានទាំងអស់ ខោអាវអីក៏ដោយ អត់មានទាំងអស់?

ញ៉ោម : អឺ!

ពិចិត្រ : អ៊ំពេលមកដល់ផ្ទះវិញ អ៊ំស្រីនៅជាមួយ ជួបគ្នា?

ញ៉ោម : នៅមកជាមួយគ្នាៗ

ពិចិត្រ : ហើយកាលនឹងកូនប៉ុន្មានពេលមកដល់វិញ?

ញ៉ោម : កូន៤នាក់មកវិញៗ

ពិចិត្រ : ចឹងចាប់ផ្តើមកសាងជីវភាពគ្រួសារឡើងវិញ ម៉េចទៅដោយវិធី?

ញ៉ោម : ដូចបាតដៃទទេរ មកៗ

ហៀង ៖ អត់មានអីទាំងអស់?

ញ៉ោម ៖ អត់មានអីទាំងអស់ ។

ហៀង ៖ ហើយធ្វើម៉េចទៅ?

ញ៉ោម ៖ យី!ធ្វើម៉េច គេចាប់ផ្ដើមធ្វើស្រែធ្វើភ្លឺអីចឹងទៅ ដល់នេះគេកសាងជាក្រុមធ្វើទៅ អ្នកណាគ្មានគោគ្មានពាពែចេះជួយធ្វើគ្នាទៅ កាលជំនាន់នឹងចុះមកនឹង ។

ហៀង ៖ អ៊ំនៅនឹងវហូត អត់មានទៅណា?

ញ៉ោម ៖ នៅវហូត ។

ហៀង ៖ អ៊ំកាលឆ្នាំ៨០ជាង អ៊ំមានពួកគេចុះមកឲ្យអ៊ំសរសេរ មានគេចុះជួបអ៊ំម្ដងទៀតនិយាយរឿងនឹងទេ?

ញ៉ោម ៖ អត់ៗដែលឃើញ ខ្ញុំមិនដែរ ។

ហៀង ៖ គេធ្វើញ្ញាតិធ្វើអី អ៊ំអត់ដឹង?

ញ៉ោម ៖ អត់ ។

ហៀង ៖ សុំសួរឈ្មោះអ៊ំឈ្មោះអី?

ញ៉ោម ៖ ខ្ញុំ កន ញ៉ោម ។

ហៀង ៖ អ៊ំអាយុប៉ុន្មាន?

ញ៉ោម ៖ ៧០ ។

ពិចិត្រ ៖ គ្រួសារអ៊ំឈ្មោះអី?

ញ៉ោម ៖ ដឹង អែម ។

ពិចិត្រ ៖ មកដល់ឥឡូវមានកូនប៉ុន្មាន?

ញ៉ោម ៖ កាលពីចុះមកនឹង បានកូនចៅ២នាក់ទៀតឡើង៦ ។

ពិចិត្រ ៖ ហើយអ៊ំអត់មានបាត់បង់សាច់ញាតិអីណា?

ញ៉ោម ៖ ប្អូនអស់អីម៉ាចឹក ។

ពិចិត្រ ៖ ប្អូនដែលលួចរត់ទៅស្រុកយួន?

ញ៉ោម ៖ បាទ!

ហៀង ៖ អស់ប៉ុន្មាននាក់ទៅ?

ញ៉ោម ៖ អស់មួយគ្រួសារ មើលបងថ្ងៃមួយ ហើយប្អូនថ្ងៃមួយ ហើយខ្ញុំតែមួយម្នាក់ឯង ។

ពិចិត្រ ៖ ចឹងសាច់ញាតិបង្កើតអត់មាន?

ញ៉ោម : ខ្ញុំនៅតែម្នាក់ឯង នេះជីដូនមួយ ឪហើយម្តាយខ្ញុំពោះមួយ ។

ហៀង : ចឹងអ៊ំមុនពេលដែលគេចាប់អ៊ំកាលឆ្នាំ៧៣នឹង អ៊ំធ្វើអី?

ញ៉ោម : អត់មានធ្វើអី គេចោទដូចខ្ញុំថាចឹង ។

ហៀង : តែអ៊ំអត់មានធ្វើស្រែ ធ្វើការងារអី?

ញ៉ោម : អត់ៗមាន ។

ហៀង : ចុះពេលនឹងអ៊ំរៀបការនៅ?

ញ៉ោម : ការបានកូន៤នាក់ហើយ ។

ហៀង : ពេល៧៣នឹង?

ញ៉ោម : អឺ!ៗ

ហៀង : ពេលគេចាប់ខ្លួនអ៊ំនឹង អ៊ំមានកូន៤នាក់ហើយ?

ញ៉ោម : ៤នាក់ ។

ពិចិត្រ : ចុះកាលនឹងអ៊ំរៀនដល់ថ្នាក់ទីប៉ុន្មាន?

ញ៉ោម : ទេ! កាលជំនាន់នឹង គេថាទី១២ តូចជាងគេ១២ ថ្នាក់តាមពិតទី៧កាលជំនាន់ ។

ពិចិត្រ : ទី៧ ជំនាន់នោះ?

ញ៉ោម : អឺ!

ពិចិត្រ : ចុះអ៊ំមកដល់សព្វថ្ងៃ អ៊ំមានដែលឮពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ញ៉ោម : ឮតាមវ៉ាដ្យូ ។

ពិចិត្រ : ឮតាមវ៉ាដ្យូថាមានដែរ?

ញ៉ោម : អឺ! ឮចេះតែឮ ។

ពិចិត្រ : អ៊ំមានដែលតាមដានទេ?

ញ៉ោម : ហ៎! បើតាមដានដាប់ ។

ពិចិត្រ : អ៊ំមានដឹងថាគេតុលាការសព្វថ្ងៃនឹង ឃុំខ្លួនបណ្តោះអាសន្នមេដឹកនាំខ្មែរក្រហមបណ្តោះអាសន្នមេដឹកនាំខ្មែរក្រហម?

ញ៉ោម : មានប៉ុន្មាននាក់ដែរយើង ។

ពិចិត្រ : អ៊ំស្គាល់ឈ្មោះទេ?

ញ៉ោម : កាំងហ្គេចអ៊ាវហៅឌុច ខៀវ សំផន ។

ហៀង ៖ អាហ្នឹងករណី០០២អ៊ំ ។ ករណី០០១ អាហ្នឹងករណីរបស់កាំងហ្គេចអាវ ។ ចា៎!ករណីទី២ នេះគឺមាន៤នាក់មេធំៗ នួន ជា ខៀវ សំផន អៀង សារី អៀង ធីរិទ្ធ ។ អ៊ំអីចឹងអ៊ំ ដែលនិយាយរឿងអីប្រាប់កូនទេអ៊ំ និយាយរឿងជំនាន់ហ្នឹងប្រាប់កូន ខស្យាហ៍និយាយទេ?

ញ៉ោម ៖ ខស្យាហ៍និយាយប្រាប់វាអីចឹងដែរ ។

ហៀង ៖ ហើយកូនអ៊ំជឿទេអ៊ំ?

ញ៉ោម ៖ ជឿមិនជឿ ។ បើកូនទី៤នោះវាដឹងហើយ ដល់កូនក្រោយនេះខស្យាហ៍និយាយប្រាប់វាអីចឹងដែរ ។ កូនទី៤អាយុប្រហែល៤-៥ឆ្នាំកាលជំនាន់ហ្នឹង ដល់ក្រោយនេះឥឡូវអាយុជិត៣០ដែរហើយ ។

វិចិត្រ ៖ អីចឹងអ៊ំបានឮពីតុលាការកាត់ទោសមេដឹកនាំដែរ តាមវ៉ាត់យូអ៊ំ?

ញ៉ោម ៖ វ៉ាត់យូ ។

វិចិត្រ ៖ ហើយចុះអ៊ំមានបានចូលរួមដាក់ពាក្យប្ដឹងទៅតុលាការហ្នឹងទេអ៊ំ?

ញ៉ោម ៖ អត់ដែលបានទេ ។

វិចិត្រ ៖ ចុះអ៊ំចង់ទេអ៊ំ?

ញ៉ោម ៖ អាហ្នឹងវា ។

ហៀង ៖ អ៊ំនៅខឹងទេ ស្មោះត្រង់ហ្មងអ៊ំ?

ញ៉ោម ៖ ខឹងដែរ តែមិនដឹងធ្វើម៉េច ។

ហៀង ៖ អ៊ំឧបមាថា កាលពីនេះហ្នឹង អ៊ំឃើញអ្នកដែលចាប់អ៊ំ អ៊ំធ្វើយ៉ាងម៉េចទៅ?

ញ៉ោម ៖ ឃើញអ្នកចាប់ហ្នឹងទុកតែនៅក្នុងពោះហ្នឹង ធ្វើម៉េចវាមិនរលាយទេ ។

ហៀង ៖ អ៊ូ!អីចឹងកហឹងនៅតែមានក្នុងខ្លួន?

ញ៉ោម ៖ នៅតែមាន តែចំណាស់នេះហើយ គិតតែធម៌អាទៅមុខវិញ ។ នឹកឃើញតែប៉ុននេះទេ ឥឡូវសង្គមគេវាបំពាក់ឲ្យអ្នកធ្វើហ្នឹងវាពិចារណាអីចឹងវិញ ។

ហៀង ៖ អីចឹង!ប៉ុន្តែអ៊ំនៅតែចាំរឿងហ្នឹងជានិច្ច?

ញ៉ោម ៖ អេស៎!ចាំច្បាស់ណាស់ ចាំអត់ភ្លេច ។

ហៀង ៖ ប៉ុន្តែអត់ហ៊ានធ្វើអីគេ?

ញ៉ោម ៖ អត់ ។

វិចិត្រ ៖ ចុះអ៊ំមកដល់ឥឡូវអ៊ំមានដែលជួបមេដឹកនាំខ្មែរក្រហមអីទេអ៊ំ?

ញ៉ាម : អត់ដែលជួបទេ ។

វិចិត្រ : ប៉ុន្តែមានស្គាល់ទេ?

ញ៉ាម : ស្គាល់ តែគេទៅបាត់អស់ហើយ គេសុទ្ធតែអ្នកពីឆ្ងាយមកអីចឹងមិនទៅណាមកណា ។

វិចិត្រ : ចុះឧទាហរណ៍បើថាគាត់នៅរស់អី អ៊ុំចង់ជួបចង់និយាយជាមួយទេ?

ញ៉ាម : ដូចខ្ញុំប្រាប់អីចឹងថា កាលអតីតកន្លងហួសទៅហើយ អារឿងជុំក្នុងនេះហ្នឹងដូចថាគ្របទុកសិន វាមិនរលាយអស់ទេ ។

ហៀង : វានៅតែជុំក្នុងហ្នឹងរលាយអត់កើតទេ?

ញ៉ាម : បាទ! ខ្ញុំចំណាស់នេះហើយ ។

ហៀង : ចា៎!អ៊ុំចុះបើគេសុំទោសអ៊ំ អាជុំក្នុងខ្លួនហ្នឹងរលាយកើតទេអ៊ំ?

ញ៉ាម : អាហ្នឹងការផ្សារបើដូចជារលាយ ក៏ដូចជាមិនរលាយដែរ ឥឡូវដូចសង្គមវាគេធ្លាក់មកវាចេះតែរំសាយទៅតាមហ្នឹងដែរ ។

ហៀង : ចា៎!អ៊ំទៅតាមពេលវេលា?

ញ៉ាម : បាទ!តាមពេលវេលា ។

វិចិត្រ : អីចឹងអ៊ំទោះបីជាអ៊ំរំសាយ តែបើអ៊ំជួបក៏អត់ទាក់ទងដែរអ៊ំ?

ញ៉ាម : គ្រាន់តែធ្វើមិនធ្វើមិនពូអីចឹងទៅ ។

ហៀង : មិនអាចរាប់អានគ្នាឡើងវិញទេ?

ញ៉ាម : បាទ! យើងធ្វើមិនដឹងធ្វើមិនពូ យើងក៏ពិចារណាថា ខ្លួនយើងក៏ចាស់ហើយ គិតតែមួយមុខ អង្គការក្នុងនេះក៏គេតាមរកតាមនេះ អីចឹងក៏តាមនេះហ្នឹងទៅ ។

ពិចិត្រ : អ៊ំឧទាហរណ៍ថា បើអ៊ំបានជួបគាត់ អ៊ំចង់ឲ្យគាត់ធ្វើអីទៅបានអ៊ំឈប់ខឹងគាត់ ដូចថាយើងមិនទៅតបតអីជាមួយគាត់ទេ ប៉ុនយើងសំណូមពរឲ្យគាត់ធ្វើអីទៅ បានយើងឈប់ខឹងជាមួយគាត់អ៊ំ?

ញ៉ាម : អេ៎!បើនេះសំណូមពរថាអីចឹង ថាកាលពីមុនអញធ្វើចេះឥឡូវធ្វើតាមបញ្ហា.....(ស្តាប់មិនបានខ្យល់ខ្លាំង) ។ គិតគូរឿងផ្លូវល្អ ប៉ុនអ្នកអស់នោះវាដឹងខ្លួនវាស្រាប់ហើយ ។

ពិចិត្រ : គិតគូផ្លូវល្អម៉េច អ៊ំណែនាំឲ្យធ្វើអី?

ញ៉ាម : តាមដូចសង្គមគេឥឡូវទាក់ទងពីអ៊ីដែររីកចំរើន យើងល្អយើងធ្វើតាមនឹង ។

ពិចិត្រ : រីកចំរើនល្អម៉េច អ៊ំអាចលើកឧទាហរណ៍បានទេ?

ញ៉ាម : រីកចំរើនល្អ ទី១យើងកសាង តាមរដ្ឋាភិបាលយើងឥឡូវ គេធ្វើការរីកចំរើនជាងមុន ។

ពិចិត្រ ៖ ចឹងអ៊ំចង់ឲ្យគាត់ទៅជួយកសាងវិហារអីចឹង?

ញ៉ោម ៖ បាទ!

ពិចិត្រ ៖ អ៊ំចង់ឲ្យគាត់ចូលរួមធ្វើការងារសង្គមអីចឹង?

ញ៉ោម ៖ បាទ!

ពិចិត្រ ៖ ហើយចឹង ឧទាហរណ៍ថាគាត់ធ្វើចឹង អ៊ំឈប់ខឹងគាត់?

ញ៉ោម ៖ គេធ្វើ....(ស្តាប់មិនបាន ខ្យល់ខ្លាំង)

ពិចិត្រ ៖ ហើយអ៊ំនឹងរាប់អានជាមួយគាត់វិញ បើគេធ្វើតាមអ៊ំចឹង?

ញ៉ោម ៖ (សើច) ។

ពិចិត្រ ៖ អ៊ំនឹងសាកល្បងនិយាយជាមួយពួកគាត់?

ញ៉ោម ៖ ចុះឥឡូវអត់មានអ្នកនិយាយនឹងផង ។ មិនដឹងពួកអស់នោះនៅណាផង ។

ពិចិត្រ ៖ បើមានអ៊ំនឹងនិយាយជាមួយពួកគាត់?

ញ៉ោម ៖ ឥឡូវបើតាមមើលកាលនោះវាសុទ្ធតែចាស់ៗដែរ វាប្រហែលមិនស្រួលងាប់បាត់ហើយ មិនតិចទេ កាលនឹងប៉ុនខ្ញុំកាលនោះអាយុ មើលកាលចប់នឹងអាយុប្រហែល៤០-៣០ជាង ឥឡូវឡើង៧០ច្ងាយហើយ ។

ពិចិត្រ ៖ អ៊ំមានអីបន្ថែមទេចុងក្រោយ ។

ហៀង ៖ អ៊ំនិយាយរឿងហើយមានអារម្មណ៍ម៉េចដែរ អ៊ំនឹកឃើញរឿងឡើងវិញខ្លាំង ឬមួយម៉េច ពេលខ្ញុំសួរទៅប៉ះពាល់អារម្មណ៍អ៊ំ?

ញ៉ោម ៖ មិនប៉ះពាល់ទេ នឹកឃើញចង់ដឹង ចង់បង្ហាញទិដ្ឋភាព ដែលកាលខ្ញុំលំបាកវេទនាចង់បង្ហាញ ឲ្យដឹងចឹងដែរ ។ ដូចថាក្មេងៗអស់នេះមិនទាន់ទេ ជំនាន់នឹង ។

ហៀង ៖ ចឹងពេលដែលអ៊ំនិយាយទៅ អ៊ំមាននឹកឃើញនិយាយរឿងវេទនាក្នុងគុកនឹង ធ្វើឲ្យអ៊ំឈឺ ចាប់ ឬមួយក៏ពិបាកអីក្នុងខ្លួន ពេលសួរចឹង អត់មាន ដូចសួរចឹង?

ញ៉ោម ៖ អារឿងឈឺចាប់នឹងវាមានហើយ ប៉ុន្តែឥឡូវនឹងដូចថា ខ្ញុំរំសាយ កាត់បន្ថយ ។

ហៀង ៖ តែពេលអ៊ំនិយាយឡើងវិញចឹង ធ្វើឲ្យអ៊ំពិបាកក្នុងខ្លួនទេ?

ញ៉ោម ៖ អត់អីទេ ។

ពិចិត្រ ៖ ចុះកន្លងមក អ៊ំមានវិធីសាស្ត្រម៉េចអ៊ំទៅ ដើម្បីកាត់បន្ថយអាកំហឹងឈឺចាប់នឹង ខ្លួនអ៊ំ ផ្ទាល់?

ញ៉ោម ៖ កាត់បន្ថយនឹកឃើញថាសង្គមឥឡូវគេការរីកចំរើន យើងកាត់បន្ថយរឿងឈឺរឿងគំនុំគុំគួន

ហៀង ៖ ស្រុបតាមសង្គមគេ?

ញ៉ោម ៖ បាទ! ស្រុបតាមសង្គមគេទៅ។

ពិចិត្រ ៖ តាមរបៀបណាទៅ អ៊ំធ្វើម៉េច?

ញ៉ោម ៖ ស្រុបនឹង តាមចឹងទៅ យើងកុំគុំគួន កុំការចងកំហឹង យើងស្រុបតាមនេះទៅ។

ពិចិត្រ ៖ អ៊ំមានអីបន្ថែមទៀតទេ?

ញ៉ោម ៖ គ្មានអី មានតែប៉ុននឹង។

ហៀង ៖ ចា៎! ចឹងខ្ញុំអរគុណច្រើន អ៊ំណា៎។

«ចប់»